ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**

-សំណុំរឿងព្រហ្មទណ្ឌលេខៈ ១១០
ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣
-សាលក្រមព្រហ្មទណ្ឌលេខៈ ៧៦ "ឆ"
ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តតាកែវ នាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ២ និង ៣០នាទីរសៀល ដោយមានសមាសភាពចូលរួមដូចតទៅៈ

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះសាលាដំបូងខេត្តតាកែវ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ១១០ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣ ដែលមានជនជាប់ចោទៈ

១-ឈ្មោះ [redacted] **សារី ហៅ ឈីត** ភេទប្រុស អាយុ២៨ឆ្នាំ (កើតថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៩៦) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកប្រមូលសំរាមរបស់ក្រុមហ៊ុនស៊ីនទ្រី មានទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួននៅ [redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] **ភាស** (រស់) ម្តាយឈ្មោះ [redacted] **ចាន់តារា** (រស់) នៅលីវ ជានីតិជន កម្រិតវប្បធម៌រៀនថ្នាក់ទី០៥ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈ គ្មាន។ (ឃុំខ្លួនថ្ងៃទី១១-០២-២០២៣)

ជាប់ចោទពីបទៈ **អំពើលួច** ប្រព្រឹត្តនៅភូមិហនុមាន ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

២-ឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** ភេទស្រី កើតថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៧៥ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរទិញអេតចាយ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] **យ៉ាន** (ស្លាប់) ម្តាយឈ្មោះ [redacted] **យ៉ន** (ស្លាប់) មានប្តី

ឈ្មោះ [redacted] **សំអឿន** (រស់) មានកូន ០២នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈ គ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទៈ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិហនុមាន ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

ដោយមានលោក [redacted] មានអត្តលេខៈ [redacted] មានអត្ត [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង**។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **បញ្ញា** ភេទប្រុស អាយុ៥៦ឆ្នាំ ជនជាតិខ្មែរ មុខរបរមេភូមិហនុមាន មានទីលំនៅភូមិហនុមាន ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ។

-បានឃើញ របាយការណ៍សរុបលេខៈ ៣៩/២០២៣ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ស្នងការដ្ឋាននគរបាលខេត្តតាកែវ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ២៧៩ ដ.ស.ព/២៣ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ២៥៣/២៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ២៧៧ ដចត/២៣ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តតាកែវ។

-បានឃើញ សាលក្រមចាត់របៀបលេខៈ ០៣ "ឆ" ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តតាកែវ។

-បានឃើញ ឯកសារផ្សេងៗក្នុងសំណុំរឿងព្រហ្មទណ្ឌខាងលើ។

## អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ:

កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ០៨ និង ០០នាទី នៅចំណុចសាលាដំណាក់សន្សំបុណ្យស្ថិតនៅភូមិហនុមាន ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ មានករណីលួចទុយោទឹកបានកើតឡើងដែលប្រព្រឹត្តដោយជនសង្ស័យឈ្មោះ [redacted] **សារី ហៅ ឈីត** ភេទប្រុស អាយុ២៧ឆ្នាំ មានទីលំនៅភូមិហនុមាន ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ បានធ្វើសកម្មភាពលួចទុយោទឹករបស់សាលាដំណាក់សន្សំបុណ្យអស់ចំនួន ១៥កំណាត់ ដោយក្នុងមួយកំណាត់មានប្រវែង ១៨០សង់ទីម៉ែត្រ។ ក្រោយពីធ្វើសកម្មភាពលួចទុយោទឹករួចហើយឈ្មោះ [redacted] **សារី ហៅ ឈីត** ក៏បានយកទុយោនោះទៅលក់ឱ្យឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** ភេទស្រី អាយុ៣២ឆ្នាំ រស់នៅភូមិហនុមាន ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ ដែលជាអ្នកទិញអេតចាយបានប្រាក់ចំនួន ១២.០០០ (មួយម៉ឺនពីរពាន់) រៀល រួចគេក៏ត្រឡប់ទៅផ្ទះវិញក៏ត្រូវបានសមត្ថកិច្ចធ្វើការសាកសួរ និងឃាត់ខ្លួនកសាងសំណុំរឿងបញ្ជូនមកសាលាដំបូងខេត្តតាកែវដើម្បីចាត់ការតាមនីតិវិធីច្បាប់។

## នាពេលសវនាការ

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សារី ហៅ ឈើត** បានឆ្លើយថា៖ ចំពោះរឿងហេតុដែលបានចោទប្រកាន់នេះគឺនៅថ្ងៃកើតហេតុខ្ញុំបាទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតមែន។ ដោយនៅថ្ងៃកើតហេតុខ្ញុំបាទបានទៅលួចទុយោទឹកនៅសាលាសន្សំបុណ្យរបស់លោកមេភូមិហនុមានពិតមែន។ ក្រោយពេលដែលខ្ញុំបាទលួចបានហើយនោះ គឺខ្ញុំបាទបានយកទៅលក់ឱ្យឈ្មោះ **កង** ដែលមានកន្លែងទិញអេតចាយនៅក្នុងភូមិនោះដែរ ដោយខ្ញុំលក់បានប្រាក់ ១២.០០០ (មួយម៉ឺនពីរពាន់) រៀល។ ពេលដែលខ្ញុំយកទៅលក់ឱ្យឈ្មោះ **កង** នោះ គឺខ្ញុំមិនបានប្រាប់គាត់ថាទុយោទឹកនោះយកមកពីណានោះទេ ហើយមីងឈ្មោះ **កង** ក៏មិនបានសួរខ្ញុំបាទអ្វីនោះដែរ។ ក្រោយពេលខ្ញុំលួចទុយោនោះលក់ឱ្យទៅឈ្មោះ **កង** រួចហើយក៏មានសមត្ថកិច្ចមកឃាត់ខ្លួនខ្ញុំបាទតែម្តង។ មូលហេតុដែលខ្ញុំលួចទុយោនេះនោះ គឺដោយហេតុថាខ្ញុំមិនមានលុយចាយទើបលួចតែម្តងទៅ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** បានឆ្លើយថា៖ ចំពោះរឿងហេតុនេះនាងខ្ញុំសូមឆ្លើយបំភ្លឺជូនតុលាការថា៖ នាងខ្ញុំបានដឹងតែពីរឿងទិញអេតចាយរបស់នាងខ្ញុំដែលទទួលទិញពីអ្នកលក់របស់ចាស់ៗ និងកំណេតកំណាត់តែប៉ុណ្ណោះ។ ហើយចំណែកឯឈ្មោះ [redacted] **សារី ហៅ ឈើត** បានយកទុយោទឹកជ័រមកលក់ឱ្យនាងខ្ញុំនោះ គឺជាទុយោទឹកចាស់ៗដែលជាកំណេតកំណាត់ចងជាបាច់តូចៗ ហើយទុយោជ័រនោះ គឺនាងខ្ញុំទទួលទិញពីឈ្មោះ [redacted] **សារី ហៅ ឈើត** ថ្លឹងជាអេតចាយដែលមានតម្លៃ ១ពាន់រៀលក្នុងមួយគីឡូ ហើយទុយោនោះ គឺមានទម្ងន់ ៧,៨គីឡូក្រាម និងនាងខ្ញុំក៏បានឱ្យលុយទៅឈ្មោះ [redacted] **សារី ហៅ ឈើត** ចំនួន ៨ពាន់រៀលទៅ។ ក្រោយពេលដែលនាងខ្ញុំទិញទុយោនេះរួចហើយនោះក៏បានយកទៅបោះដាក់នៅគំនរអេតចាយដូចរបស់របរអេតចាយផ្សេងទៀតដែរ។ ក្រោលពេលខ្ញុំទិញរួចហើយនោះក៏មានបងប្រធានភូមិហនុមានគាត់បានមកសួរនាងខ្ញុំថាមានឃើញគេយកទុយោជ័រមកលក់ដែរ ឬទេពេលនោះនាងខ្ញុំថាឃើញមានឈ្មោះ [redacted] **សារី ហៅ ឈើត** យកមកលក់ឱ្យនាងខ្ញុំខ្លះដែរ តែឈ្មោះនេះគេបានប្រាប់ថាទុយោនោះ គឺជារបស់ឪពុកគេ។ ពេលនោះដែរលោកប្រធានភូមិគាត់បានប្រាប់ថាឈ្មោះ [redacted] **សារី ហៅ ឈើត** បានលួចទុយោនេះ នាងខ្ញុំដឹងបែបនេះក៏បានប្រគល់ទុយោនោះឱ្យទៅលោកប្រធានភូមិវិញដោយមិនយកប្រាក់ពីគាត់នោះទេ ហើយខ្ញុំបានប្រាប់លោកមេភូមិថា "បើដឹងថាទុយោនេះឈ្មោះ **ឈើត** គេបានលួចយកមកពីសាលាបុណ្យនោះ គឺមិនទទួលទិញជាដាច់ខាត"។ ក្រោយមកលោកប្រធានភូមិក៏បានយកទៅទុកវិញជាធម្មតាទៅ។ នាងខ្ញុំមិនមានចេតនាក្នុងការទទលទិញទុយោជ័ររបស់ឈ្មោះ **ឈើត** អ្វីសូម្បីតែបន្តិច ហើយមូលហេតុដែលខ្ញុំបានទិញទុយោនេះក៏ដោយសារតែខ្ញុំឃើញឈ្មោះ **ឈើត** យកទុយោនេះមកមានសភាពបាក់ៗ និងជាកំណេតកំណាត់ខ្លីៗ ដែលមិនអាចយកទៅតភ្ជាប់ដើម្បីប្រើប្រាស់បានទៀតនោះទេ និងគិតថាជារបស់អេតចាយផងនោះទើបនាងខ្ញុំទទួលទិញតែម្តងទៅ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សារី ហៅ ឈើត** បានឆ្លើយថា៖ ពេលខ្ញុំកំពុងតែថ្លឹងគីឡូលក់ទុយោនោះ គឺខ្ញុំក៏បានប្រាប់ចែឈ្មោះ **កង** ថាទុយោនេះជាទុយោរបស់ឪពុកខ្ញុំ។ ខ្ញុំមិនបានប្រាប់ឈ្មោះ **កង** ថាទុយោនេះខ្ញុំលួចគេយកមកលក់នោះទេ។

-ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **បញ្ញា** បានឆ្លើយថាៈ កាលពីថ្ងៃដែលមានរឿងហេតុនេះកើតឡើងនោះ គឺខ្ញុំបាទបានទៅសាលាសន្សំបុណ្យសដែលស្ថិតនៅក្នុងភូមិហនុមានរបស់ខ្ញុំនេះ ពេលទៅដល់ក៏ឃើញបាត់ទុយោជ័រអស់មួយចំនួន។ ក្រោយពេលដែលខ្ញុំបានដឹងថាបាត់ទុយោហើយនោះក៏បានតាមរកមើលទៅ និងទៅសួរនៅកន្លែងទិញអេតចាយ ហើយក៏បានសួរទៅកាន់ក្មួយឈ្មោះ **កង** ថា "ក្មួយៗឯងទិញទុយោអេតចាយនេះទិញទុយោមកពីណា" ហើយក្មួយឈ្មោះ **កង** គាត់បានឆ្លើយថា "គាត់ទិញពីអា **ឈីត**" ហើយខ្ញុំក៏និយាយថា "ចប់ ទុយោនៅកន្លែងបុណ្យពូទើបតែទិញយកមកតប្រហែលជា ១០០ម៉ែត្រឥឡូវកាត់ខ្ទេច" ហើយក្មួយឈ្មោះ **កង** ប្រាប់ថា "ឈ្មោះ **ឈីត** បានយករបស់ឪវាមកលក់ឱ្យខ្ញុំ"។ ហើយពេលនោះដែរក្មួយឈ្មោះ **កង** ក៏បានប្រគល់ទុយោនោះឱ្យមកខ្ញុំយកមកទុកធ្វើជាភស្តុតាង ដោយក្មួយឈ្មោះ **កង** មិនបានយកប្រាក់ពីខ្ញុំនោះទេ រួចហើយខ្ញុំក៏បានប្ដឹងចូលទៅសមត្ថកិច្ចឱ្យស្រាវជ្រាវរកអ្នកដែលលួចទុយោនោះ និងបានកំណត់ថាឈ្មោះ [redacted] **សារី ហៅ ឈីត** នេះជាអ្នកលួច ហើយសមត្ថកិច្ចបានឃាត់ខ្លួនឈ្មោះ **ឈីត** តែម្ដង។ នៅក្នុងរឿងនេះក្នុងនាមខ្ញុំជាដើមបណ្ដឹង និងជាមេភូមិហនុមាន គឺមិនទាមទារសំណងអ្វីនោះទេ ដោយសុំឱ្យតុលាការបញ្ចប់រឿងនេះត្រឹមនេះចុះមិនចង់វែងឆ្ងាយបន្តទៀតនោះទេ។ ខ្ញុំសូមបន្ថែមថា ចំពោះឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** នៅក្នុងស្រុកភូមិគាត់ជាមនុស្សដែលជួយឧបត្ថម្ភស៊ីម៉ង់ត៍ និងសម្ភារៈមួយចំនួននៅក្នុងសាលាសន្សំបុណ្យនេះដែរ ហើយគាត់ក៏ជាមនុស្សដែលចូលចិត្តជួយយកអាសារគ្នាដែរ ដោយមានសកម្មភាពអ្វីគាត់ជួយរហូតតាមតិចក្ដីច្រើនក្ដី។

-ចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] **រដ្ឋា** បានឆ្លើយថាៈ ចំពោះឈ្មោះ **ឈីត** នេះខ្ញុំធ្លាប់ឃើញគេបានលួចខ្សែភ្លើងនៅសាលាបុណ្យម្ដងដែរ ដោយគេបានលួចកាត់ខ្សែភ្លើងយកមកដុតនៅខាងក្រោយផ្ទះខ្ញុំឡើយហ៊ុយជុបតែម្ដង។ ហើយពាក់ព័ន្ធនឹងរឿងហេតុនេះវិញនោះ គឺកាលពីថ្ងៃកើតហេតុឈ្មោះ **ឈីត** ក៏បានកាត់ទុយោពីសាលាបុណ្យយកទៅលក់ ហើយក៏មានអ្នកស្រុកបាននិយាយថាឃើញមានឈ្មោះ **ឈីត** បានលួចកាច់ទុយោនេះដើរកាត់ក្នុងភូមិ និងបានយកទៅលក់អេតចាយបាត់ហើយ។ ចំពោះឈ្មោះ **ឈីត** នេះគេជាមនុស្សដែលដើរអុកឡុកអ្នកភូមិជាប្រចាំ និងជាមនុស្សដែលបង្កការរំខានដល់អ្នកស្រុកអ្នកភូមិទៀតផង។ ខ្ញុំមានតួនាទីជាប្រជាការពារភូមិនៅភូមិហនុមាននេះឯង ។ ចំពោះរឿងហេតុផ្សេងទៀខ្ញុំពុំដឹងនោះទេ។

-ចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] **ពេជ្រ** បានឆ្លើយថាៈ ខ្ញុំបាទបានឃើញឈ្មោះ [redacted] សារី ហៅ ឈីត ធ្វើសកម្មភាពកាន់ទុយោនៅសាលាសន្សំបុណ្យ ហើយឈ្មោះ [redacted] សារី ហៅ ឈីត បានលើកទុយោទឹកយកទៅលក់អេតចាយឱ្យបងឈ្មោះ **កង** ដែលជាអ្នកទទួលទិញអេតចាយចាស់ៗ។ ចំពោះរឿងហេតុផ្សេងទៀតខ្ញុំបាទពុំដឹងនោះទេ។

-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំដោយសុំរក្សានូវការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខៈ ២៧៩ ដ.ស.ព/២៣ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ ទុកជាបានការដដែល។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** បានធ្វើសេចក្ដីសន្និដ្ឋានថាៈ បើពិនិត្យទៅលើអង្គហេតុ ក៏ដូចជាសាច់រឿងដែលមានជាក់ស្ដែងឃើញថាទាក់ទងនឹងអំពើទទួលផលចោរកម្មនេះ គឺកូនក្ដីរបស់ខ្ញុំបាទឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** គឺគាត់មិន

បានដឹងថាឈ្មោះ [redacted] **សាវិ ហៅ ឈីត** បានទៅលួចទុយោជ័រពីសាលាបុណ្យមកនោះទេ ដូច្នេះក៏ធ្វើឱ្យកូនក្តីខ្ញុំបាទទទួលទិញ ហើយការទទួលទិញនេះទៀតសោតក៏កូនក្តីខ្ញុំបានទិញឱ្យតម្លៃទុយោនេះក៏ជាតម្លៃនៃអេតចាយដែរ ដោយសារទុយោនេះជាទូទៅមានប្រវែង ០៤ម៉ែត្រឯណោះ ក៏ប៉ុន្តែទុយោដែលឈ្មោះ **ឈីត** បានយកមកលក់នេះ គឺមានប្រវែងតែប្រហែលជា ០១ម៉ែត្រតែប៉ុណ្ណោះ ហេតុនេះទើបកូនក្តីខ្ញុំគិតថាទុយោនេះជាទុយោអេតចាយ និងគេឈប់ប្រើប្រាស់ទើបគាត់ទទួលទិញតែម្តង។ មួយវិញទៀតបើផ្អែកទៅលើមាត្រា ៣៩៩ នៃក្រមព្រហ្មទណ្ឌ បានចែងអំពីអំពើទទួលផលចោរកម្ម គឺមានន័យថា "ជាអំពើដែលទទួល លាក់បាំង រក្សាទុក ឬបញ្ជូនវត្ថុអ្វីមួយដោយដឹងថាវត្ថុនោះបានមកពីផលឧក្រិដ្ឋ ឬមិជ្ឈិម" ក៏ប៉ុន្តែជាក់ស្តែងកូនក្តីខ្ញុំបាទឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** ដែលបានទទួលទិញទុយោនេះពីឈ្មោះ [redacted] **សាវិ ហៅ ឈីត** នោះ គឺជាទុយោដែលបានលួចគេយកមកលក់នោះទេ ហេតុនេះទើបកូនក្តីខ្ញុំទទួលទិញ ហើយម្យ៉ាងទៀតនៅពេលដែលដើមបណ្តឹងបានទៅរកទុយោនោះទៀតសោតក៏កូនក្តីខ្ញុំបាទបានប្រគល់ឱ្យទៅលោកពូមេភូមិដែលជាដើមបណ្តឹងវិញដែរ ដោយមិនបានគិតប្រាក់នោះទេ។ ណាមួយជាក់ស្តែងកូនក្តីខ្ញុំបាទក៏ជាពលរដ្ឋល្អម្នាក់នៅក្នុងភូមិឃុំដែលតែងតែចូលរួមគ្រប់កម្មវិធីផ្សេងៗផងដែរ ហើយសាលាសន្សំបុណ្យនេះក៏កូនក្តីខ្ញុំតែងតែធ្លាប់ចូលរួមកងសាងបន្តិចបន្តួចខ្លះៗដែរ។ កូនក្តីខ្ញុំបាទពុំមានចេតនាទុច្ចរិតណាមួយក្នុងការទទួលទិញសម្ភារ ឬរបស់របរចោរនោះទេ។ ដូច្នេះក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** សូមស្នើសុំដល់តុលាការមេត្តាលើកលែងបទចោទប្រកាន់មកលើកូនក្តីខ្ញុំបាទពីបទៈ **ទទួលផលចោរកម្ម** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ឬក៏បន្ធូរបន្ថយទោយដល់កូនក្តីខ្ញុំបាទ។

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **សាវិ ហៅ ឈីត** ថាៈ ខ្ញុំបាទសំណូមពរដល់តុលាការមេត្តាបន្ធូរបន្ថយទោសផង ព្រោះខ្ញុំបាទមានការសោកស្តាយ និងបានដឹងពីកំហុសដែលបានប្រព្រឹត្តហើយៗសន្យាថាពេលចេញពីពន្ធនាគារវិញឈប់ប្រព្រឹត្តអំពើនេះទៀតហើយ។

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** ថាៈ នាងខ្ញុំសំណូមពរដល់តុលាការមេត្តាលើកលែងការចោទប្រកាន់មកលើរូបនាងខ្ញុំពីអំពើខាងលើនេះ ដោយហេតុថានៅថ្ងៃដែលឈ្មោះ [redacted] **សាវិ ហៅ ឈីត** បានយកទុយោមកលក់ឱ្យនាងខ្ញុំនោះ គឺនាងខ្ញុំមិនបានដឹងថាទុយោជ័រនេះឈ្មោះនេះបានលួចយកមកលក់ឱ្យនាងខ្ញុំនោះទេ ហើយសព្វថ្ងៃនេះនាងខ្ញុំក៏មានមុខរបរទិញអេតចាយផងដែរ ហេតុនេះនាងខ្ញុំមិនមានចេតនាទិញទុយោរបស់ចោរនោះទេ។

**-ក្រោយពីបាន** ស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

**-ក្រោយពីបាន** ស្តាប់ចម្លើយបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

**-ក្រោយពីបាន** ស្តាប់ចម្លើយបំភ្លឺរបស់សាក្សី ។

**-ក្រោយពីបាន** ពិនិត្យឯកសារ និងភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿង ។

**-ក្រោយពីបាន** ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។



Scanned with CamScanner

**-ក្រោយពីបាន** ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** ។

**-ក្រោយពីបាន** ស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ។

**-ក្រោយពីបាន** ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-ក្រោយពីធ្វើការស៊ើបសួរតាមនីតិវិធីចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយលេខៈ ២៥៣/២៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣ ដោយបានសម្រេចបញ្ជូនជនត្រូវចោទ៖

១.១-ឈ្មោះ [redacted] **សារី ហៅ ឈើត** ភេទប្រុស អាយុ២៨ឆ្នាំ មកជំនុំជម្រះពីបទៈ **អំពើលួច** ប្រព្រឹត្តនៅភូមិហនុមាន ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

១.២-ឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** ភេទស្រី កើតឆ្នាំ១៩៧៥ មកជំនុំជម្រះពីបទៈ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិហនុមាន ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

២-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **សារី ហៅ ឈើត** ចម្លើយបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ឃើញថាៈ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ០៨ និង ០០នាទី ស្ថិតនៅចំណុចសាលាដំណាក់សន្សំបុណ្យក្នុងភូមិហនុមាន ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ ពិតជាមានជនជាប់ចោទឈ្មោះ [redacted] **សារី ហៅ ឈើត** បានធ្វើសកម្មភាពលួចទុយោទឹកជ័រពីសាលាដំណាក់សន្សំបុណ្យអស់ចំនួន ១៥កំណាត់ប្រាកដមែន។ ក្រោយមកក៏ត្រូវបានដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **បញ្ញា** ដែលមានតួនាទីជាមេភូមិបានប្តឹងចូលសមត្ថកិច្ច រួចហើយសមត្ថកិច្ចបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] **សារី ហៅ ឈើត** តែម្តង។ ក្រោយពីធ្វើការសាកសួរជនជាប់ចោទរូបនេះបានឆ្លើយសារភាពថាៈ ខ្លួនបានលួចយកទុយោទឹកជ័រទាំងនោះទៅលក់ឱ្យឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** បានប្រាក់ចំនួន ១២.០០០ (មួយម៉ឺនពីរពាន់) រៀល ដោយខ្លួនមិនបានប្រាប់ទៅឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** ថាទុយោទឹកជ័រនោះខ្លួនបានលួចគេនោះទេ គឺប្រាប់ថាជាទុយោរបស់ឪពុកខ្លួនទើបឈ្មោះ [redacted] **សោភ័ណ្ឌ ហៅកង** ទទួលទិញតែម្តង។ ក្រោយមកដើមបណ្តឹងឈ្មោះ **ញ៉ាញ់ បញ្ញា** ក៏បានទៅផ្ទះរបស់ឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** ដើម្បីរកទុយោទឹកជ័រនោះ ដោយឈ្មោះ **អ៊ុំ សោភ័ណ្ឌ** ហៅ កង ឆ្លើយថាខ្លួនពិតជាបានទិញទុយោទឹកជ័រពីឈ្មោះ [redacted] **សារី ហៅ ឈើត** ពិតមែនក៏ប៉ុន្តែខ្លួនមិនបានដឹងថាជាទុយោដែលជននេះបានលួចពីគេនោះទេ ដោយឈ្មោះ [redacted] **សារី ហៅ ឈើត** អះអាងថាជាទុយោរបស់ឪពុកគេ ទើបខ្លួនទទួលទិញតែម្តង។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** ដែលបានឆ្លើយបដិសេធថាៈ នៅថ្ងៃដែលឈ្មោះ [redacted] **សារី ហៅ ឈើត** បានយកទុយោមកលក់ឱ្យខ្លួននោះ គឺគេមិនបានប្រាប់ខ្លួនថា

គេយកទុយោនេះមកពីណានោះទេ ដោយគេគ្រាន់តែបានប្រាប់ថាជាទុយោរបស់ឪពុកគេ មួយវិញទៀតដោយខ្លួនឃើញថាទុយោនេះមានកាច់ជាកំណាត់ខ្លីៗ និងជារបស់អេតចាយដែលមិនអាចប្រើប្រាស់បន្តបានទៀត ទើបខ្លួនទទួលទិញតែម្តងទៅ។ ដែលចម្លើយបដិសេធរបស់ជនជាប់ចោទនេះ អាចឱ្យតុលាការជឿជាក់បានដោយហេតុថា: ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **សាវិ ហៅ ឈីត** ថា: ក្រោយពេលដែលខ្លួនលួចទុយោពីសាលាសន្សំបុណ្យបានហើយនោះខ្លួនបានយកទៅលក់ឱ្យឈ្មោះ **កង** (ឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង**) ដែលជាកន្លែងទិញអេតចាយនៅក្នុងភូមិហនុមាន បានប្រាក់ ១២.០០០ (មួយម៉ឺនពីរពាន់) រៀល និងពេលដែលខ្លួនយកទៅលក់នោះ គឺខ្លួនមិនបានប្រាប់ឈ្មោះ **កង** ថាទុយោទឹកនោះខ្លួនយកមកពីណានោះទេ និងខ្លួនគ្រាន់តែបានប្រាប់បន្តិចថាជាទុយោរបស់ឪពុកខ្លួន។ មួយវិញទៀតផ្អែកតាមចម្លើយបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេ ណីឈ្មោះ [redacted] **បញ្ញា** ក៏បានបញ្ជាក់ផងដែរថា: ក្រោយពេលដែលខ្លួនដឹងថាបាត់ទុយោខ្លួនក៏បានទៅសួរនៅកន្លែងទិញអេតចាយ និងបានជួបក្មួយឈ្មោះ **កង** (ឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង**) ដោយគាត់បានឆ្លើយថា "គាត់ទិញទុយោពីឈ្មោះ **ឈីត**" ហើយក្មួយឈ្មោះ **កង** ប្រាប់ថា "ឈ្មោះ **ឈីត** បានយករបស់ឪវាមកលក់ឱ្យខ្លួន"។ ក្រោយមកក្មួយឈ្មោះ **កង** ក៏បានប្រគល់ទុយោនោះឱ្យមកខ្លួនរក្សាទុកវិញ ដោយក្មួយឈ្មោះ **កង** មិនយកប្រាក់ពីខ្លួននោះទេ។ ដែលចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **សាវិ ហៅ ឈីត** និងចម្លើយបំភ្លឺរបស់ដើមបណ្តឹងឈ្មោះ [redacted] **បញ្ញា** នេះសបញ្ជាក់ឱ្យឃើញថាឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** ពិតជាពុំមានចេតនាក្នុងការទទួលទិញសម្ភារៈ ដែលជារបស់ចោរនោះទេ និងពិតជាពុំបានជាប់ពាក់ព័ន្ធនឹងអំពើខាងលើដូចការចោទប្រកាន់ឡើយ។

៤-យល់ឃើញថា: ពុំមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** ភេទស្រី កើតថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៧៥ ពីបទ: **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិហនុមាន ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ នោះទេ។ ហេតុនេះគប្បីតុលាការសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** រួចខ្លួនពីបទចោទតាមបញ្ញត្តិមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥-យល់ឃើញថា: អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] **សាវិ ហៅ ឈីត** ដែលបានធ្វើសកម្មភាពលួចទុយោទឹករបស់សាលាដំណាក់សន្សំបុណ្យចំនួន ១៥កំណាត់ដើម្បីយកទៅលក់ ដោយចេតនាទុច្ចរិត គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសប៉ះពាល់ដល់ទ្រព្យសម្បត្តិសាធារណៈទៀតផង ហើយអំពើនោះទៀតសោតត្រូវបានច្បាប់ហាមឃាត់ និងកំណត់ថាជាបទ: **អំពើលួច** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៦-យល់ឃើញថា: មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **សាវិ ហៅ ឈីត** ភេទប្រុស អាយុ ២៨ឆ្នាំ (កើតថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៩៦) ពីបទ: **អំពើលួច** ប្រព្រឹត្តនៅភូមិហនុមាន ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

៧-យល់ឃើញថា: ជនជាប់ចោទឈ្មោះ[redacted]**សារិ ហៅ ឈើត** ភេទប្រុស អាយុ២៨ឆ្នាំ (កើតថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៩៦) គឺជានីតិជនដែលមានស្មារតីយល់ដឹង និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសព្រហ្មទណ្ឌដែលកើតចេញពីអំពើដែលខ្លួនបានប្រព្រឹត្ត។

៨-តាមការប្តឹងសុំរបស់តំណាងអយ្យការដោយសុំរក្សានូវការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ: ២៧៩ ដ.ស.ព/២៣ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ ទុកជាបានការដដែលលើជនជាប់ចោទឈ្មោះ[redacted]**សោភ័ណ្ឌ ហៅ កង** ពីបទ: **ទទួលផលចោរកម្ម**។ តុលាការយល់ឃើញថា: ការប្តឹងសុំនេះពុំមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់នោះទេ គប្បីតុលាការពុំសម្រេចតាមការប្តឹងសុំនេះផ្ទុយទៅវិញតំណាងអយ្យការប្តឹងសុំឱ្យផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ[redacted]**សារិ ហៅ ឈើត** ពីបទ: **អំពើលួច**។ តុលាការយល់ឃើញថា: ការប្តឹងសុំនេះមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់ គប្បីតុលាការសម្រេចតាមការប្តឹងសុំនេះ។

៩-តាមសេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] **សោភ័ណ្ឌ ហៅ កង** ស្នើសុំដល់តុលាការសម្រេចលើកលែងការចោទប្រកាន់លើកូនក្តីខ្លួនផងដោយហេតុថា: កូនក្តីខ្លួនឈ្មោះ[redacted]**សោភ័ណ្ឌ ហៅ កង** ពុំបានដឹងថាឈ្មោះ[redacted]**សារិ ហៅ ឈើត** បានទៅលួចទុយោជ័រពីសាលាបុណ្យយកមកលក់ឱ្យខ្លួននោះទេ ហើយកូនក្តីខ្លួនក៏ពុំមានចេតនាទុច្ចរិតណាមួយក្នុងការទទួលទិញសម្ភារ ឬរបស់របរចោរនោះដែរ។ ក្នុងករណីនេះតុលាការយល់ឃើញថា: ការស្នើសុំរបស់មេធាវីខាងលើនេះមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់ ហេតុនេះគប្បីតុលាការទទួលយកមកពិចារណា។

១០-យល់ឃើញថា: នាពេលសវនាការជនជាប់ចោទឈ្មោះ[redacted]**សារិ ហៅ ឈើត** មានការភ្ញាក់រឭក និងសារភាពទទួលស្គាល់នូវកំហុសរបស់ខ្លួន ព្រមទាំងសន្យាថាឈប់ប្រព្រឹត្តអំពើខាងលើនេះទៀតហើយ ក៏ប៉ុន្តែឃើញថាកន្លងមកជននេះជាមនុស្សដែលដើរអុកឡុក និងបង្កការរំខានដល់អ្នកស្រុកភូមិជាញឹកញាប់។ ហេតុដូច្នេះគប្បីតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារលើជននេះកំណត់ចំនួន **០១ (មួយ) ឆ្នាំ**។

១១-យល់ឃើញថា: ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]**បញ្ញា** ពុំបានទាមទារសំណងពីជនជាប់ចោទឈ្មោះ[redacted]**សារិ ហៅ ឈើត** នោះទេ។ ហេតុនេះតុលាការនឹងមិនពិចារណាត្រង់ចំណុចនេះនោះទេ។

## ហេតុដូច្នេះសម្រេច

១-ឱ្យជនជាប់ចោទឈ្មោះ[redacted]**សោភ័ណ្ឌ ហៅ កង** ភេទស្រី កើតថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៧៥ (អត្តសញ្ញាណខាងលើ) រួចខ្លួនពីបទចោទ បទ: **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិហនុមាន ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

២-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ[redacted]**សារិ ហៅ ឈើត** ភេទប្រុស អាយុ២៨ឆ្នាំ (កើតថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៩៦) (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន **០១ (មួយ) ឆ្នាំ** ពីបទ:



Scanned with CamScanner

**អំពើលួច** ប្រព្រឹត្តនៅភូមិហនុមាន ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ នៅសាលាដំបូងខេត្តតាកែវ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សារី ហៅ ឈីត** និងឈ្មោះ [redacted] **សោភ័ណ្ឌ ហៅ កង** និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **បញ្ញា** ។

-ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted] ហត្ថលេខា និងត្រា: [redacted]

---

(បានថតចម្លងត្រឹមត្រូវតាមលិខិតដើម)

ថ្ងៃចន្ទ ១៣រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

តាកែវ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣

**ក្រឡាបញ្ជីសវនាការ**

បានឃើញ

តាកែវ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

[redacted]

[redacted]



Scanned with CamScanner